សម្លេងខ្មែរនៅបរទេស

# លោកស៊ីម_វ៉ារ “ទទួលទោសកំហុស!”

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១៩ តុលា ២០០៤

(១៩៤១)

ស្តេចសីហនុ ក្នុងអាយុ១៩ឆ្នាំ ជាស្តេចក្មេងឬ«ស្តេចពាល»មួយអង្គ មិនទាន់ដឹងខ្យល់អ្វី... ដែលស្រាប់តែបានឡើងសោយរាជ្យជាម្ចាស់ផែនដីនៃនគរក្រុងកម្ពុជា ។ មានអ្នកនយោបាយបីនាក់ គឺលោកសឺង-ង៉ុកថាន់ ប៉ាជ-ឈឺន និងស៊ឹម-វ៉ារ ដែលបានធ្វើសកម្មភាពចូកថែវ ជម្រុញឲ្យខ្សែចរន្តនៃប្រវត្តិសាស្ត្រហូរទៅតាមទិសព្រួញបែបដូចនេះ ។ ក៏ប៉ុន្តែ ក្នុងប្រការនេះ, លោកស៊ឹម-វ៉ារបានថ្លែងប្រាប់ខ្ញុំថា លោក«ទទួលទោសកំហុស» ធ្ងន់ជាងគេទាំងអស់...

គឺនៅក្នុងឆ្នាំ១៩៦៧ទៅហើយ ពេលដែលខ្លួនខ្ញុំបានទៅធ្វើជាសហការីនៃឪពុកធំរបស់ខ្ញុំ... លោកស៊ឹម-វ៉ារ នៅក្នុងទិន្នានុប្បវត្តិ «ខ្មែរឯករាជ្យ» ដែលខ្ញុំបានដឹងរឿងសំងាត់ខាងលើនេះ ។ ឪពុកធំរបស់ខ្ញុំបានប្រាប់ខ្ញុំថា ដែលសម្តេចសីហនុបានឡើងសោយរាជ្យ ជាព្រះករុណាម្ចាស់ផែនដីនោះ... ក៏ដោយសារ«កំហុសរបស់អ៊ុំ»ដែរ ។ ពាក្យថា «កំហុស» ក្នុងមាត់អ្នកនយោបាយ, តើមានន័យដូចម្តេចទៅហ្ន៎ ?...

ព្រោះតាំងពីខ្ញុំដឹងក្តីកាលណាមក ខ្ញុំមិនទាន់ជឿថា មានអ្នកនយោបាយណាម្នាក់ ទោះនៅក្នុងអតីតកាលក្តី ទោះនៅក្នុងបច្ចុប្បន្នកាលក្តី ទទួលខ្លួនឯងថា ខ្លួនឯងធ្វើខុសឡើយ... ឬយល់ព្រមសារភាពដោយសុទ្ធចិត្តឯងៗ ដោយស្មោះបរិសុទ្ធអស់ពីពោះពីពុងចំពោះអ្នកដទៃ ថាខ្លួនធ្វើខុសក្រៅពីការគេរុញច្រានឲ្យទាល់ច្រកប៉ុណ្ណោះ ។ ពីព្រោះការទទួលកំហុសក្នុងនយោបាយ គឺជា«សេចក្តីស្លាប់របស់ខ្លួនឯង»... មិនមែនជាអវត្តមាននៃរូបកាយទេ ប៉ុន្តែជា«ការស្លាប់នៃឧត្តមគតិរបស់ខ្លួនឯង» ។ អ្នកនយោបាយដែលទទួលខ្លួនខុស គឺត្រូវឈប់ធ្វើនយោបាយ ។ គឺប្រហែលគ្នានឹងបង្ខំឲ្យមនុស្សសាមញ្ញធម្មតាឈប់ដកដង្ហើម ។

សម្តេចសីហនុក្តី, លោកខៀវ-សំផនក្តី... ឬក៏សូម្បីឯកឧត្តនអ៊ិន-តាំក្តី ក៏មិនដែលទទួលខ្លួនខុសដែរ មកទល់សព្វថ្ងៃនេះ ។ ហើយបើកាលណាគេម្នាក់ៗទទួលខ្លួនថា«ខុស»... គឺគ្រាន់តែបានសេចក្តីថា គេមិនខុសតែប៉ុណ្ណោះឯង, ឬធ្ងន់ជាងនេះទៅទៀត «ខុសដែរ...ក៏ប៉ុន្តែ»... ។ ឧទាហរណ៍ដូចមកទល់បច្ចុប្បន្ននេះ គ្មានដែលបានទទួលខ្លួនលោកថាខុសម្តងណាសោះ គឺលោកភ្លឺស្វាងតែមួយចប់... ស្វាងតាំងតែពីឆ្នាំ១៩៤១ រហូតដល់ឆ្នាំ២០០៤ ក៏នៅតែទ្រង់ឈ្វេងយល់ត្រូវរហូត... ស្វាងមិនព្រមស្វាង ។ លោកផ្លាស់ប្តូរនយោបាយវិលក្បុង ដូចសត្វថ្លែនដូរពណ៌ ពេលដែលសម្តេចធ្វើជាប្រធានសង្គមរាស្ត្រនិយម លោកបានពិឃាត«ពួកខ្មែរសេរី» និង «ពួកខ្មែរក្រហម» (១៩៥៥-១៩៧០), ពេលដែលលោកឡើងធ្វើជាប្រធានខ្មែរក្រហម... នៅទីក្រុងប៉េកាំង លោកបានដឹកនាំពួកយួនហាណូយ ហើយនិងពួកខ្មែរកុម្មុយនិស្ត ឲ្យមកពិឃាតពួកខ្មែរលន់-នល់និងពួកសង្គមចាស់ ដែលសុទ្ធសឹងជាកូនចៅព្រះអង្គ កាលពីសម័យសង្គមរាស្ត្រនិយម (១៩៧០-១៩៧៩) ។ នៅក្នុងទសវត្សរ៍១៩៨០... លោកបានធ្វើនយោបាយរួបរួមជាមួយពួកខ្មែរក្រហម ហើយនិងពួកសាធារណរដ្ឋ ដើម្បីច្បាំងជាមួយពួកយួនឈ្លានពាន ហើយនិងពួកហ៊ុន-សែន ។ លុះដល់ទសវត្សរ៍១៩៩០... លោកបានទៅចុះចូលជាមួយពួកហ៊ុន-សែន ដើម្បីច្បាំងជាមួយពួកខ្មែរក្រហមវិញម្តង ។ ឃើញថាអ្នកដែលខុស គឺសុទ្ធសឹងជាពួកអ្នកដទៃទៀតទាំងអស់... គឺពួកលន់-នល់ (ពួកកូនចៅផ្ទាល់របស់សម្តេច ចំណែកអ្នកដទៃទៀត សុទ្ធសឹងជាពួកកូនចៅមិនផ្ទាល់... ហើយបើនិយាយថា កូនចៅលោកផ្ទាល់មិនស្មោះនឹងលោកទៅហើយ តើទៅសង្ឃឹមលើអ្នកណាថាគេស្មោះនឹងលោកទៅកើត?) ។ អ្នកខុសគឺ«ពួកខ្មែរសេរី», «ពួកខ្មែរក្រហម», «ពួកចក្រពត្តិអាមេរិក», «ពួកយួនហាណូយ», ពួកសូវៀត, ពួកចិនប៉េកាំង ព្រមទាំងរាស្ត្រខ្មែរទូទៅក៏ខុសដែរ, ទេតែសម្តេចសីហនុមួយអង្គគត់ ។ ចំណែកលោកខៀវ-សំផនមកដល់សព្វថ្ងៃវិញ... គេថា«ខ្លួនគេខុសមែនពិត ក៏ប៉ុន្តែគេពុំបានសម្លាប់មនុស្សណាដែលគ្មានទោសកំហុសនោះទេ...» ។ ចំណែកប៉ុល-ពតវិញ សាហាវជាងគេមែនទេ... រហូតទៅដល់ថ្ងៃស្លាប់ (១៩៩៨) ប៉ុល-ពតមិនបានទទួលខ្លួន, ខុសក៏មិនថាខ្លួនគាត់ខុស-ត្រូវក៏មិនថាខ្លួនគាត់ត្រូវ ។ ប៉ុល-ពតមិនសូវជាខ្វល់ខ្វាយនឹងយោបល់ពិភពលោកនោះទេ ។ មនុស្សតែម្នាក់គត់ រស់នៅក្នុងអាថ៌កំបាំងនៃ«អង្គការលើ» តទល់នឹងការខ្ពើមរអើមមួយភពផែនដីបាន ។ គួរសរសើរដែរ, ព្រោះខ្លួនមាឌតូច ឥទ្ធិពលតិច ចំណោះស្តើង... អ្នកនយោបាយកំទេចកំទីម្នាក់ ក្នុងប្រទេសតូចមួយដែលគេមិនដែលស្គាល់, អតីតគ្រូបង្រៀនសាលាឈ្នួលម្នាក់ ដែលមានសំដីទន់ភ្លន់, ស្រាប់តែមានកម្លាំងទឹកចិត្តប្រហែលមិនស្មើរ ឬក៏មិនស្មើទេ... ប៉ុន្តែដូចជាលើស អ៊ីត្លែរ, ស្តាលីន, ម៉ៅ-សេទុងទៅទៀត ។ រីឯជនផ្តាច់ការអន្តរជាតិមាឌយក្សទាំងប៉ុន្មាន ប្រសិនបើគេទៅគាស់ខ្មោចពួកគាត់មកវិញ ឲ្យមកថ្លែងការណ៍ដល់សារពត៌មានអន្តរជាតិ ក៏ច្បាស់ជាពួកគាត់គ្មានផ្លូវទទួលខ្លួន ថាពួកគាត់ខុសនោះដែរ ។ ហើយប្រសិនបើពួកគាត់ត្រូវកសាងឧក្រិដ្ឋកម្មឡើងវិញ ដែលគាត់បានប្រព្រឹត្តក្នុងអតីតកាល គឺច្បាស់ជាគាត់នឹងកសាងឡើងវិញម្តងទៀតជាមិនខានឡើយ ។

នៅទីបំផុត បើនិយាយពីឯ.ឧ.អ៊ិន-តាំវិញ ដែលសព្វថ្ងៃកំពុងកសាងសីលធម៌ស្រង់ដើម ជា«តាឥសីកំបាក់កំពុក»ម្នាក់នៅអារីសូណា លោលធ្លាប់បានរំលឹកពេលវេលាធំៗទាំងអស់នៅក្នុងអតីតកាល ដែលឯកឧត្តមបានគាំទ្រសម្តេចឪជាអម្ចាស់ ។ ពេលសម័យទាមទារឯករាជ្យពីបារាំង ! ពេលឆ្នាំ១៩៦០, ដែលលោកបានកេណ្ឌប្រជានុរាស្ត្រ (ខេត្តតាកែវ) ជាមួយនិងលោកទឹម-ដុង (ប្រតិភូក្រុងកែប) មកថ្វាយព្រះពរសម្តេចឪឲ្យក្លាយទៅជាព្រះប្រមុខរដ្ឋ ព្រមទាំងបានដង្ហែសម្តេចឪ «រហូតដល់ទីអវសាន», ជួយព្រះអង្គធ្វើប្រជាមតិប្រកបដោយជោគជ័យត្រចះត្រចង់ចំពោះ«សង្គមរាស្ត្រនិយម» ។ នៅឆ្នាំ១៩៧២... នៅចំកណ្តាលទន្លេនៃសាធារណរដ្ឋខ្មែរ...ឯ.ឧ.អ៊ិន-តាំ ក្នុងនាមជាមេដឹកនាំគណបក្សប្រជាធិបតេយ្យ ជាមួយនិងលោកឌុក-រ៉ាស៊ី ហើយនិងលោកចៅ-សៅ ក្នុងយុទ្ធនាការបោះឆ្នោតតតាំងនឹងឯ.ឧ.លន់-នល់... លោកបានប្រកាសធ្វើជាមេធាវីឲ្យសម្តេចសីហនុ ត្រឡប់ចូលទីក្រុងភ្នំពេញវិញ...(ក្នុងប្រការឲ្យស្តេចក្រហមមកអារកពួកលន់-នល់និងពួកសិរិមត:) ។ រហូតដល់ឆ្នាំ១៩៨០ ដែលឯកឧត្តមបានសុខចិត្តដង្ហែរសម្តេចឪ ឲ្យរហូតដល់ទីចប់នោះទៀត, លោកអ៊ិន-តាំភ្លេចនឹកឃើញតែព្រឹត្តិការណ៍មួយគត់...ថ្វីបើជាព្រឹត្តិការណ៍មួយដ៏សំខាន់គួរសមដែរ គឺលោកភ្លេចថា លោកបានដង្ហែរព្រះកូណាសីហនុវរ្ម័ន (ឲ្យធ្លាក់ដាំដូង) ក្នុងព្រឹត្តិការណ៍១៨មិនា១៩៧០... ដែលក្នុងឋានៈជាប្រធានរដ្ឋសភាស្តីទី... លោកបានក្លាយទៅជា «កូនសោរមួយដ៏

សំខាន់» ក្នុងរដ្ឋប្រហារ«តាមច្បាប់» ទម្លាក់ប្រមុខរដ្ឋខ្មែរ ។ គិតសព្វៗទៅ... ពេលដែលលោកអ៊ិន-តាំបានចោទសម្ដេចសីហនុ ក្នុងថ្ងៃ១៨មិនាថាជាស្ដេចសក្តិភូមិជាមួយឯ.ឧ.ទ្រិញ-វ៉ាញ់ ព្រមទាំងបាន«លួចសរសើររៀមច្បងឯ.ឧ.ឧត្តមសេនិយឯកលន់-នល់ពីយូយារណាស់មកហើយ». ក៏នៅតែលោកមិនខុស ។ ប៉ុន្តែពេលដែលឯកឧត្តមអ៊ិន-តាំបានបោកបញ្ឆោតមេដឹកនាំខ្មែរសេរីម្នាក់ គឺលោកព្រៀប-អ៊ិន ឲ្យមកចូលសឹង «សង្គមរាស្ត្រនិយម» បណ្ដាលឲ្យសម្ដេចសីហនុចាប់ដាក់ក្នុងទ្រុង បណ្ដើរដូចស្វា នៅមុខមនុស្សកំសាករាប់ម៉ឺនសែននាក់នៃហ្វូងសមាជនៅវាលព្រះមេរុ... រួចហើយត្រូវស្ដេចបញ្ជាឲ្យយកទៅបាញ់ចោលយ៉ាងសាហាវយង់ឃ្នងនៅត្រពាំងក្រឡឹង... នោះក៏ជាអំពើត្រឹមត្រូវមួយដែររបស់ឯ.ឧ.អ៊ិនតាំ (ខ្ញុំហាក់ដូចជាមានអារម្មណ៍ម្ដងម្កាល ថាស្ដេចសីហនុប្រហែលជាមិនធ្លាក់ដល់ថ្នាក់ឆ្កួតលីលាម្ល៉ឹងពេកទេ... ប្រសិនបើគ្មានព្រះរាជបំរើបញ្ជើចបញ្ជើរឲ្យឡប់អាចម៍ខ្សៀវ តួយ៉ាងដូចឯ.ឧ.អិន-តាំ !!) ។

( សុភាសិតរបស់ DIOGÈNE ទស្សនវិទូក្រិក ៖ ជនម្នាក់បានសួរគាត់ថា ៖ តើសត្វណាមួយដែលខាំបណ្ដាលឲ្យឈឺចាប់ជាងគេបំផុត ? នៅក្នុងចំណោមពួកកាចសាហាវ (ពួកជនពាល), គាត់ឆ្លើយ, គឺពួកនិយាយអាក្រក់ពីគេ ។ នៅក្នុងចំណោមពួកអ្នកចេះដឹង, គឺពួកនិយាយបញ្ជើចបញ្ជើរ...) ។

❑ ❑

❑

វិលត្រឡប់មកលោកស៊ឹម-វ៉ារវិញ, ក្នុងឆ្នាំ១៩៦៧... ពេលនោះសម្ដេចសីហនុទើបតែបានបញ្ជាឲ្យលោក ចៅ-សេង «ឧបរាជឆ្វេង» របស់ទ្រង់ប្លន់ដណ្ដើមយកកាសែត «Le Dépêche du Cambodge» ចេញពីផ្ទះគាត់... ដែលគាត់មានឋានៈជាចាងហ្វាងនយោបាយ ។ លោកស៊ឹម-វ៉ារក៏បានទៅបង្កើតទិន្នានុប្បវត្តិមួយទៀតជាភាសាខ្មែរ គឺកាសែត «ខ្មែរឯករាជ្យ»... (ចាងហ្វាងនយោបាយ ស៊ឹម-វ៉ារ, ចាងហ្វាងការផ្សាយថោង លឹមហួង, និពន្ធនាយក ជូ-ថានី) ។ ថ្វីបើមានការជំទាស់ពីមិត្តភក្តិស៊ូជាច្រើនក្នុងជំនាន់អាណានិគមបារាំងក៏ដោយ ថាកុំឲ្យគាត់ធ្វើនយោបាយធ្វើអ្វី ក្នុងឆ្នាំ១៩៦៦-៦៧... ព្រោះកាលៈទេសៈមិនអនុញ្ញាតឲ្យទេ... ពីព្រោះគ្មានច្រកចេញទេ, ដោយសេរីភាពនយោបាយនៅប្រទេសកម្ពុជា ក្នុងសម័យ១៩៦៦-៦៧នោះ មាន«មិនស្មើនឹងសេរីភាពនយោបាយកាលពីសម័យអាណានិគម»នោះផង... ក៏ប៉ុន្តែលោកស៊ឹម-វ៉ារនៅតែចចេសធ្វើតាមចរិតរបស់គាត់ ដែលហ៊ាននិយាយការពិតខ្លាំងៗ ចំពោះព្រឹត្តិការណ៍ប្រកបដោយគ្រោះថ្នាក់... នៅពេលដែលអ្នកផងទូទៅគ្រាន់តែហ៊ានគិតនៅក្នុងពោះ (Dire tout haut ce que tant le monde pense tout bas) ។ ជាហេតុបណ្ដាលឲ្យសម្ដេចឪជាអម្ចាស់ ស្រែកបង្អើលតាមវិទ្យុ ឲ្យរាស្ត្រមកធ្វើឃាតលោកស៊ឹម-វ៉ារ ព្រមទាំងបញ្ជាឲ្យលោកចៅ-សេង ព្រមទាំងលោកសក្តិប្រាំ ហ៊ូវ-ហាំងស៊ីន (កុមីស្សែរសង់ត្រាល់ភ្នំពេញ) កេណ្ឌបាតុករខ្លាន់ខ្លាប់ មកឡោមព័ទ្ធបំផ្លិចបំផ្លាញគេហស្ថានលោកស៊ឹម-វ៉ារផង ( ឋិតនៅវិថីបូទុមសុរិយាវង្ស ក្បែរស្ពានចាស់ នៅចំពីមុខផ្ទះលោកម៉ី-ស៊ីចន ក្នុងសង្កាត់បារាំង)... ព្រមទាំងឲ្យមកកំទេចរោងពុម្ពកាសែតខ្មែរឯករាជ្យផង ឋិតនៅតាមផ្លូវកម្ពុជាក្រោម មិនឆ្ងាយប៉ុន្មានពីផ្សារថ្មី ។ ពួកបាតុករបានវាយដំម៉ាស៊ីនកាសែតឲ្យខូចយ៉ាងដំណំ ព្រមទាំងប្រមូលក្រដាសរាប់គោន មកហែកបាចសាចពេញថ្នល់ (ចំនួនខូចខាតប្រហែលខ្ទង់ជិតពីរលានរៀល...ហើយសុទ្ធសឹងជាប្រាក់ខ្ចីគេ និងជាប្រាក់ចូលហ៊ុនភ្ជាយកមកធ្វើសារពត៌មាននេះ) ។

ក្រោយពីកើតឧប្បត្តិហេតុ លោកអ៊ុំស៊ឹម-វ៉ារ ព្រមទាំងគ្រួសាររបស់គាត់... ដោយការណែនាំបញ្ចុះបញ្ចូលពីក្រុមញាតិនិងមិត្តឆ្ងាយទាំងអស់ ក៏បានដាច់ចិត្តទៅសំណាក់នៅផ្ទះក្មួយគាត់ម្នាក់ឈ្មោះលោកហ៊ីង-គុនថាប់ (ប្អូនបង្កើតរបស់លោកហ៊ីង-គន្ធល់) ទៅទួលគោក ។ ក្នុងការខកចិត្តឬស្រុតចិត្តយ៉ាងខ្លាំង... ដែលខ្ញុំកម្រជួបប្រទះនៅក្នុងរូបអ្នកនយោបាយស៊ឹម-វ៉ារ... ខ្ញុំឮគាត់មានប្រសាសន៍មកកាន់ខ្ញុំ ដោយមិនទាំងសម្លឹងមុខខ្ញុំផងថា ៖ «អ៊ុំគ្មានជំនឿទៅលើអនាគតរបស់ស្រុកយើងទៀតទេ... ហើយអ៊ុំក៏គ្មានជំនឿថានរណាអាចធ្វើអ្វីទៀតកើតដែរ» ។

ដូច្នេះឆ្នាំ១៩៦៦-១៩៦៧នេះ... គឺជាឆ្នាំកំណើតនៃការមិនសប្បាយចិត្តទូទៅនៃប្រជាពលរដ្ឋខ្មែរ ចំពោះសម្ដេចសីហនុព្រះប្រមុខរដ្ឋ...ចំណែកកាសែត «ខ្មែរឯករាជ្យ» របស់លោកស៊ឹម-វ៉ារ គឺជា«និមិត្តរូប»នៃការមិនសប្បាយចិត្តនោះឯង (Le Malaise)... ដូច្នេះហើយបានជាសម្ដេចឲ្យគេរំលាយចោលដោយ «ច្បាប់ព្រៃ...ឬច្បាប់តាមផ្លូវថ្នាក់» Loi de la rue ។

ប៉ុន្តែរឿងធំបំផុតដែលគ្មាននរណាដឹង (ប្រហែលមានតែលោកស៊ឹមវ៉ារ និងមនុស្ស៨-១០នាក់ទៀតដែលដឹង)... ដែលជាកត្តាសំខាន់បំផុត បណ្ដាលឲ្យផ្ទុះព្រឹត្តិការណ៍១៨ មិនា ១៩៧០ ។

រឿងឫសគល់នៃសោកនាដកម្មខ្មែរតែម្ដង គឺរឿង«ទំនាស់វាំង»...គឺរឿងចំបាំងរវាងស្ដេចម៉ែ (វាំងហ្លួង) និងស្ដេចកូន (វិមានរដ្ឋចំការមន)... គឺការប៉ះទង្គិចគ្នាតតផ្លូវកែបាន រវាងព្រះមហាក្សត្រីយានីកុសុមៈនារីរ័ត្ន និងសម្ដេចប្រមុខរដ្ឋនរោត្តម-សីហនុ ។

សម្ដេចសីហនុ ដោយដឹងថា អំណាចរបស់លោកកាន់តែរង្គោះរង្គើរហើយ ដូចជាចង់របូតផុតពីដៃលោកហើយ ក៏មានគោលបំណងចង់សោយរាជ្យលើរាជបល្លង្កឡើងវិញ ដោយពិធីរាជាភិសេកជាមួយអ្នកម្នាងម៉ូនិក ។ ដែលជាការបណ្ដាលឲ្យមានការប្រឆាំងដាច់អហង្ការពីព្រះមហាក្សត្រីយានី ។ បើសម្ដេចសីហនុចង់សោយរាជ្យសម្បត្តិឡើងវិញ វាំទាល់តែសោយលើ «ខ្មោចរបស់ទ្រង់» ពីព្រោះថា...ពេលព្រះកូណាននរោត្តម-សីហនុបានដាក់រាជ្យក្នុងឆ្នាំ១៩៥៥ ព្រះអង្គបានសន្យាជាឧឡារិកចំពោះមុខប្រជានុរាស្ត្រ និងទេព្តារក្សាស្វេតឆ័ត្រ ថាទ្រង់មិនវិលត្រឡប់មកកាន់រាជសម្បត្តិវិញទេ ។ ពីឆ្នាំ១៩៦៦ ទៅដល់ឆ្នាំ១៩៧០ ម៉ែហើយនិងកូន អស់មើលមុខគ្នាត្រង់ជាម៉ែហើយនិងជាកូនទៀតហើយ...។ ព្រះរាជាណាចក្រខ្មែរក៏ក្លាយទៅជាមានវាំងពីរ...។

ពេលដែលលោកស៊ឹម-វ៉ារត្រូវទៅសំណាក់នៅផ្ទះលោក ហ៊ីង-គុនថាប់ (ចាងហ្វាងក្រុមហ៊ុនស្ហែល) នៅទួលគោក... គឺជាពេលដែលគាត់បាន «និទាន» រឿងសម្ងាត់របស់វាំងឲ្យខ្ញុំស្ដាប់ខ្លះៗ ដែលបណ្ដាលឲ្យខ្ញុំព្រឺក្បាលខ្លាកៗ ។ ជាបឋម លោកស៊ឹម-វ៉ារមានប្រសាសន៍ថា...ដែលគេមិនធ្វើឃាតគាត់ ឬមិនធ្វើឃាតដល់ក្រុមនិពន្ធ «ខ្មែរឯករាជ្យ» គឺដោយសារបានគុណាបុណ្យព្រះមហាក្សត្រីយានីជាអ្នកគាំពារ ។

ទី២- លោកបញ្ជាក់ថា ដែលសម្ដេចសីហនុបានឡើងសោយរាជ្យ ក៏ជាកំហុសរបស់គាត់ដែរ...ដូចខ្ញុំបានពោលនៅលើរួចមកហើយ (ប៉ុន្តែជាកំហុសដែលគាត់បានស្ដាយក្រោយ ឬមិនបានស្ដាយក្រោយនោះ...ខ្ញុំមិនដឹងទេ...ពីព្រោះខ្ញុំមិនសួរគាត់...) ។

ទី៣- លោកស៊ឹម-វ៉ារពោលថា ព្រះមហាក្សត្រីយានី ថ្វីត្បិតតែជាស្រីភេទ... ប៉ុន្តែមានប្រាជ្ញាខ្ពង់ខ្ពស់ណាស់ ហើយមានចិត្តរឹងប៉ឹងដូចប្រុស... តាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ ។ ចំណែកស្ដេចសីហនុវិញ មានជាតិជាស្ដេចតែសំបកក្រៅ តែមានក្រយៅជាខ្ញុំគេ (ពេលនោះខ្ញុំចេះតែឆ្ងល់ថា លោកស៊ឹម-វ៉ារម្ដេចក៏ស្រឡាញ់ហើយគោរពម្ដាយ...ហើយម្ដេចក៏ស្អប់កូនម្ល៉េះ ?

ទី៤- អំពីសម្ដេចក្រុមព្រះស៊ីសុវត្ថិ-មុនីរេត...

លោកស៊ឹម-វ៉ារបានពោលថា ជាមនុស្សម្នាក់ត្រង់ (Un homme sin

cère)... ចិត្តលោកយ៉ាងម៉េច សំដីលោកយ៉ាងដូច្នោះឯង មិនចេះមានពុតត្បុតម្នៃរម្នូរម្នែម្នួយរបៀបជា«ញី»...ឬលាក់មុខទុកគូថកណ្ដាលវាលដូចសម្ដេចសីហនុនោះទេ ។ អំពីស្ពាតអូទ្បាំពិកនៅភ្នំពេញជាដើម ដែលស្រូបថវិកាជាតិអស់រាប់លានដុល្លារនោះ... សម្ដេចក្រុមព្រះមុនីរេតបាននិយាយជាភាសាបារាំងថា ៖ «C'est le tombeau du Sangkum) («គឺផ្នូរនៃរបបសង្គមរាស្ត្រនិយម») ។

ទី៥- គឺចំណុចនេះហើយដែលលោកសុឹម-វ៉ារបានហាមប្រាមខ្ញុំដាច់ខាត មិនឲ្យផ្សាយឬមិនឲ្យប្រាប់នរណាម្នាក់ទៀតសោះ... ក៏ប៉ុន្តែក្នុងពេលឥឡូវនេះ ខ្ញុំមិនអាចលាក់ទុកការសម្ងាត់នេះបានទៀតឡើយ ។ លោកសុឹម-វ៉ារបានពោលថា ថ្ងៃមួយលោកបានបង្កើតសមាគមនិស្សិតខ្មែរមួយ... ក្នុងប្រការស្វែងរកអាហារូបករណ៍ ដើម្បីទៅធ្វើការសិក្សានៅបរទេស ។ លោកក៏បានទៅស្នើសុំសម្ដេចក្រុមព្រះសុីសុវត្ថិ-មុនីរេត..កាលនោះហៅថា «ព្រះអង្គម្ចាស់អធិបតី»... (កូនស្ដេចបំរុងសោយរាជ្យ) ដើម្បីឲ្យលោកធ្វើជាប្រធាន ។ ជាអកុសល សម្ដេចក្រុមព្រះមុនីរេតបានឆ្លើយមកលោកសុឹម-វ៉ារវិញថា ៖ «...កុំឲ្យកូនខ្មែររៀនសូត្រច្រើនពេក នាំតែពិបាកគ្រួត» ។ ព្រដូចនេះ លោកសុឹម-វ៉ារកើតសេចក្ដីទោមនស្ស ហើយក៏បានទៅបំផុសបំផុលចលនាប្រជាប្រិយមួយ ប្រឆាំងនឹងសម្ដេចមុនីរេត ដែលជាហេតុបណ្ដាលឲ្យ«ព្រះអង្គម្ចាស់អធិបតី» ត្រូវរបូតរាជសម្បត្តិ ។

❏ ❏

❏

ឥឡូវនេះ, ខ្សែចរន្តប្រវត្តិសាស្ត្របានហូររសាត់បាត់ទៅឆ្ងាយពន់ពេកទៅហើយ... ដូចតែទឹក«ស្ទឹងហូរឥតមានវិលត្រឡប់» ។ ក៏ប៉ុន្តែតើយើងគួរស្ដាយកំហុសរបស់លោកសុឹម-វ៉ារឬទេដែលបានធ្វើចលនាសម្ងាត់កំចាត់សម្ដេចក្រុមព្រះសុីសុវត្ថិ-មុនីរេតពីរាជបល្លង្ក... ហើយបែរជាជ្រើសរើស«ស្ដេចពាល» មិនទាន់ជ្រុះបង្អើយពីក្បាល ឈ្មោះនរោត្តម-សីហនុ មកសោយរាជ្យជំនួសវិញ ? ធម្មតា... ការប្រព្រឹត្តខុស គឺជាកំហុសទី១... ចំណែកការស្ដាយកំហុស វាជាកំហុសទី២... ពីព្រោះថា អ្វីដែលយើងបានប្រព្រឹត្តហួសទៅហើយ យើងមិនអាចកែប្រែវាឲ្យមានលក្ខណៈទ្រង់ទ្រាយ បានដូចដើមវិញទេ ។ អង្ករដាំជាបាយទៅហើយ...មិនអាចក្លាយទៅជាអង្ករវិញបានទេ...

ក៏ប៉ុន្តែតាមយោបល់ខ្ញុំ យ៉ាងហោចណាស់ ក៏សូមឲ្យកំហុសរបស់លោកសុឹម-វ៉ារ បានក្លាយទៅជាមេរៀនប្រវត្តិសាស្ត្រ សំរាប់កូនចៅជំនាន់ក្រោយផងដែរ ។ ជាពិសេសនៅក្នុងបច្ចុប្បន្ននេះតែម្ដង ប្រជាពលរដ្ឋខ្មែរកំពុងតែត្រូវការជ្រើសរើសយកស្ដេចសោយរាជ្យ នៅក្នុងចំណោមព្រះអង្គម្ចាស់ពីរអង្គ... ដើម្បីកាន់កាប់ព្រះរាជបល្លង្កនៃប្រទេសកម្ពុជា !

ទី១- តើយើងត្រូវជ្រើសរើសយកព្រះអង្គម្ចាស់នរោត្តម-សីហមុនីឬ ?? បើដូច្នេះ យើងច្បាស់ជាដើរតាមគន្លងនៃកំហុសរបស់លោកសុឹមវ៉ារទៀតហើយ... គឺយើងនឹងបានជ្រើសរើសយកស្ដេចភ្លីភ្លើម្នាក់ ចេះតែរាំច្រៀង ហើយដែលជាប់«ឃុំព្រលឹង» ដោយមហាអំណាចបារាំងនិងវៀតណាម ។ គឺដូចដែលលោកសុឹម-វ៉ារបានជ្រើសរើស យក«ស្ដេចពាល»សីហនុ ឲ្យឡើងសោយរាជ្យកាលពីសម័យមុនដូច្នោះដែរ...

ទី២- តើយើងត្រូវជ្រើសរើសយកសម្ដេចក្រុមព្រះនរោត្តម-រណឫទ្ធិ ? ថ្វីបើសម្ដេចក្រុមព្រះអង្គនេះមានអំពើឆ្គាំឆ្គងខ្លះ អប្រជាប្រិយ ដូចតែ«សម្ដេចក្រុមព្រះមុនីរេត»សម័យមុន ក៏ប៉ុន្តែទ្រង់ក៏មានលក្ខណៈល្អខ្លះៗដែរ ដែលគួរយកជាបានការ...

ក/ ស្ដេចក្រុមវាំងស្ទើរតែទាំងអស់ (បុប្ផាទេវី, ចក្រពង្ស, សិរីវុឌ្ឍ, វជរ៉ា...) គឺសុទ្ធសឹងជាបរិវារដាច់ថ្លៃរបស់អ្នកម្នាងម៉ូនិក ។ មានតែទ្រង់រណឫទ្ធិទេ ដែលហ៊ានជំទាស់ជាមួយឪពុកខ្លួនឯង... ពីព្រោះទ្រង់មាន«ឯករាជ្យខាងផ្លូវគំនិត» (Indépendence d'esprit)..។ មនុស្សដូច្នេះ មិនងាយជាប់«ឃុំគ្រង»របស់ជនណាម្នាក់ទេ ។ មនុស្សដូច្នេះ គឺជាមនុស្សដែលមានជំនឿលើខ្លួនឯង !

ខ/ ទ្រង់រណឫទ្ធិជាសាស្ត្រាចារ្យច្បាប់នៅសកលវិទ្យាល័យបារាំង ។ លក្ខណៈនេះមិនធម្មតាទេ ។ ការដែលលោកសម-រង្ស៊ីបន្តុះបង្អាប់ថា ទ្រង់មិនចេះភាសាបារាំង គឺជាការតិទៀនដោយឈ្លានិសព្យាបាទ (ពីព្រោះលោកសម-រង្ស៊ីជាខ្ញុំកញ្ជះដាច់ថ្លៃរបស់អ្នកម្នាងម៉ូនិក... ចុះសម្ដេចសីហនុរៀនសូត្របានតែត្រឹមថ្នាក់ទី៤នៃអនុវិទ្យាល័យ ម្ដេចក៏គេមិនរំព្វកផង)

គ/ ទ្រង់រណឫទ្ធិធ្លាប់បានធ្វើការតស៊ូប្រឆាំងយួនជាមួយលោកខៀវសំផន ។ រឿងនេះមិនធម្មតាទេ... បើគេថាទ្រង់រណឫទ្ធិ «ឃុំព្រលឹង» របស់លោកហ៊ុន-សែន ដែលមានយួនពីក្រោយខ្នង ហ៊ុន-សែនក៏ត្រូវជាប់«ឃុំព្រលឹង»របស់រណឫទ្ធិ ដែលមានអ្នកតស៊ូនៅពីក្រោយខ្នង តួយ៉ាងដូចជាញ៉ឹក-ប៊ុនឆៃនិងសេរី-កុសល ។

ឃ/ ទ្រង់រណឫទ្ធិធ្លាប់ធ្វើយុទ្ធនាការបោះឆ្នោត... ធ្លាប់កាន់តំណែងជានាយករដ្ឋមន្ត្រី... កំពុងតែកាន់កាប់តំណែងជាប្រធានសភា ។ រឿងនេះមិនធម្មតាទេ...

ង/ លក្ខណៈធម្មតារបស់ទ្រង់... គឺទ្រង់រណឫទ្ធិមានប្រពន្ធកូនដូចគេឯងធម្មតា ។ ចំណែកព្រះអង្គម្ចាស់សីហមុនី... ជាជនខ្ទើយ រឿងនេះមិនធម្មតាទេ, តើនរណាទៅជ្រើសរើសយកកូនស្ដេចដែលគ្មានប្រពន្ធមកមកធ្វើជាព្រះមហាក្សត្រ ? គឺមានតែឲ្យទ្រង់តំណាងឲ្យជនខ្ទើយ ?

ក៏ប៉ុន្តែខ្លួនខ្ញុំ គ្រាន់តែជាអ្នកសារពត៌មានប៉ុណ្ណោះទេ... ភារកិច្ចនៃការជ្រើសរើសស្ដេចខាងលើនេះ...ខ្ញុំសូមទុកឲ្យមិត្តអ្នកអានធ្វើការពិចារណានិងសំរេចផងចុះ ។៚